ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ

## ក្រុមស្រាវជ្រាវទី៧៖

លោក ប៉ូ ប៊ុន្លន, ណុច ស្រីនាង, ឈឺន លីន

# ប្រធានបទ៖ ការយល់ឃើញរបស់គរុនិស្សិតលើកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិ.+២)

គម្រោងស្រាវជ្រាវអប់រំ

# មាតិកា

01 ៖ សេចក្តីផ្តើម

02 ៖ រំឭកទ្រឹស្តី

03 ៖ វិធីសាស្ត្រស្រាវជ្រាវ

04 ៖ លទ្ធផលស្រាវជ្រាវ

05 ៖ សេចក្តីសន្និដ្ឋាន



# ជំពូក១៖ សេចក្តីផ្តើម

## ១.១.សាវតារនៃការស្រាវជ្រាវ

• និន្នាការអប់រំសកលនិងតំបន់មានការប្រែប្រួលយ៉ាងលឿនដោយសារការវិវត្តនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាក៏ដូចជាតម្រូវការជាក់ស្តែងរបស់សង្គមជាតិ។ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤ ផ្តោតសំខាន់លើការអប់រំប្រកបដោយគុណភាពដែលប្រទេសនីមួយៗត្រូវតែសម្រេចឱ្យបានត្រឹមឆ្នាំ២០៣០។

• វិទ្យាស្ថានជាតិអប់រំបានបង្កើតគណៈកម្មការកែលម្អកម្មវិធីបណ្តុះបណ្តាលនៅគ្រប់មុខវិជ្ជាសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិ.+២) ដោយមានការសហការជាមួយភាគីពាក់ព័ន្ធដូចជាខេបសាកលវិទ្យាល័យភ្នំពេញ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ។

• ការកសាងក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិតតាមមុខវិជ្ជា និងផែនការបណ្តុះបណ្តាលត្រូវបានធ្វើបច្ចុប្បន្នភាព និងពិនិត្យឡើងវិញស្របទៅតាមផែនការយុទ្ធសាស្ត្រ និងសកម្មភាពនៅក្នុងផែនការប្រតិបត្តិរបស់វិទ្យាស្ថានជាតិអប់រំ។

## ១.២.បញ្ហានៃការស្រាវជ្រាវ

• ការសិក្សាពីប្រសិទ្ធភាពរបស់កម្មវិធីការពេញចិត្តរបស់គរុនិស្សិត និងផលជះនៃកម្មវិធី ការពេញចិត្តរបស់គរុនិស្សិត និងផលជះនៃកម្មវិធីមិនទាន់បានសិក្សាទូលំទូលាយ និងជាក់លាក់ឡើយ(Sims et al., 2015)។

• គម្លាតក្នុងការអភិវឌ្ឍកម្មវិធី ជាពិសេសសកម្មភាពបណ្តុះបណ្តាលបន្តនៅមានកម្រិត និងការចូលរួមការផ្សព្វផ្សាយព័ត៌មានត្រឡប់ ដល់ភាគីពាក់ព័ន្ធនៅមានចំណុចខ្វះខាត ( Guideline MoEYs, 2017 )។

• ការបណ្តុះបណ្តាលត្រូវចំណាយច្រើន និងការមិនសម្រេចបានតាមវត្ថុបំណង និងពេលវេលាដែលបានកំណត់ក្នុងកម្មវិធី។ កត្តាសំខាន់គឺការបង្ហាញទំនាក់ទំនង និងការបន្សីគ្នារវាងធាតុចូល ដំណើរការ និងការសម្រេចបានលទ្ធផលដែលបានគ្រោងទុក (IIEP, 2019) & ( Vartennie,A.2023 )។

## ១.៣.បញ្ហានៃការស្រាវជ្រាវ (ត)

• យោងតាមរបាយការណ៍របស់វិទ្យាស្ថានជាតិអប់រំសិង្ហបុរីស្តីពីការវាយតម្លៃលើកម្មវិធីសិក្សារបស់វិទ្យាស្ថានជាតិអប់រំកម្ពុជាបានបង្ហាញថាគរុនិស្សិតត្រូវការពេលវេលាបន្ថែមទៅលើការសិក្សាមុខវិជ្ជាដូចជាគរុកោសល្យ ការស្រាវជ្រាវ និងចិត្តវិទ្យាអប់រំ (របាយការណ៍វិទ្យាស្ថានជាតិសិង្ហបុរី, 2020)។

• របាយការណ៍វាយតម្លៃACCផ្តោតលើកម្មវិធីបណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តមបរិ.+២ វិទ្យាស្ថានជាតិអប់រំបង្ហាញថាមានសមាសភាពមួយចំនួនដែលត្រូវផ្តោតការយកចិត្តទុកដាក់ នឹងត្រូវពង្រឹងរួមមាន (១) ការវាយតម្លៃកម្មវិធី និងការផ្តល់ព័ត៌ត្រឡប់ឃើតយ៉ាវ (២) ការធ្វើបច្ចុប្បន្នភាពរូបវន្តនិងឧបករណ៍សិក្សា (៣)ការលើកទឹកចិត្ត និងកម្មវិធីតម្លើងឋានៈសាស្ត្រាចារ្យជាផ្លូវការមិនទាន់បានតម្លើង (របាយការណ៍ ACC, 2025)។

## ១.៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

សិក្សាចំពោះគរុនិស្សិតដែលបានទទួលការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិ.+២) ជំនាន់ទី១ លើមុខវិជ្ជាឯកទេសចំនួន៤គឺៈ គណិត រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

១. ផ្តល់ទស្សនៈវិស័យសម្រាប់ការអនុវត្តតាំងពីដំណាក់កាលត្រៀមរៀបចំផែនការបណ្តុះបណ្តាល ដំណាក់កាលអនុវត្ត និងដំណាក់កាលវាយតម្លៃលទ្ធផល។

២. បង្ហាញដល់គណៈគ្រប់គ្រង គ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំបានយល់ពីប្រសិទ្ធភាពនៃការបង្រៀនទាំងចំណុចល្អ និងចំណុចគួរកែលម្អដើម្បីបង្កើនសមត្ថភាព និងឧត្តមភាព។

## ១.៦.គោលបំណងនៃការស្រាវជ្រាវ

១. សិក្សាពីស្ថានភាពនៃកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិ.+២)នៅវិទ្យាស្ថានជាតិអប់រំ។

២. កំណត់ពីបញ្ហាប្រឈម និងដំណោះស្រាយការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិ.+២)នៅវិទ្យាស្ថានជាតិអប់រំ។

## ១.៧. សំណួរស្រាវជ្រាវ

១. តើស្ថានភាពនៃកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិ.+២)នៅវិទ្យាស្ថានជាតិអប់រំមានស្ថានភាពដូចម្តេច?

២. តើមានបញ្ហាប្រឈម និងដំណោះស្រាយអ្វីខ្លះលើដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិ.+២)នៅវិទ្យាស្ថានជាតិអប់រំ?

# ជំពូក២៖ រំឭកទ្រឹស្តី

- ក្របខណ្ឌធានាគុណភាពផ្ទៃក្នុងត្រូវបានបង្កើតឡើងដើម្បីត្រៀមលក្ខណៈសម្បត្តិ និងលទ្ធភាពក្នុងការបង្កើតសេណារីយ៉ូ យុទ្ធសាស្ត្រ និងការប្រកួតប្រជែង (NIE, 2024) ។

- ការអភិវឌ្ឍវប្បធម៌គុណភាពតាមរយៈការធានាគុណភាពផ្ទៃក្នុងមានសារសំខាន់សម្រាប់ស្ថាប័ន(IIEP,2017)។

- ស្ថាប័នវាយតម្លៃផ្ទៃក្នុងដោយផ្តោតលើស្ថានភាពនៃការបង្រៀន ដំណើរការ និងលទ្ធផលសិក្សាដែលជាគោលបំណងមូលដ្ឋាន។ការវាយតម្លៃផ្ទៃក្រៅផ្តោតការវាយតម្លៃកម្មវិធី និងការទទួលស្គាល់អាជីព និងការវាយតម្លៃពីដៃគូអន្តរជាតិ(IIEP,2017)

- ការវាយតម្លៃពីតម្រូវការបណ្តុះបណ្តាល(Training Needs Assessment) ជាវិធីសាស្ត្រក្នុងការកំណត់ស្ថានភាពបច្ចុប្បន្ន ដើម្បីបំពេញគម្លាតតាមរយៈបញ្ហាដែលត្រូវប្រែក្លាយទៅជាតម្រូវការបណ្តុះបណ្តាល(IIEP, 2019)។

- ការប្រៀបធៀបការវាយតម្លៃកម្រិតកម្មវិធីAUNបង្ហាញថាកម្មវិធីបណ្តុះបណ្តាល NIE មានសមាសភាគ និងសូចនាករមួយចំនួនដែលត្រូវបំពេញបន្ថែម(ឯកសារវាយតម្លៃកម្មវិធីAUN + AsTEN)។

- ទ្រឹស្តីវាយតម្លៃកម្មវិធីជាប្រព័ន្ធ (Inputs-Process-Outputs)និងទ្រឹស្តីមួយចំនួនទៀតរួមមាន Kirkpatrick Model និងADDIE Model ដែលជាមូលដ្ឋានក្នុងការវាយតម្លៃប្រសិទ្ធភាពកម្មវិធី។

# និយមន័យនៃពាក្យគន្លឹះ

១. **កម្មវិធីបណ្តុះបណ្តាលគរុនិស្សិត**

២. **គ្រូឧទ្ទេស វិធីសាស្ត្របង្រៀន និងធនធានរូបវន្ត**

ការវាយតម្លៃការពេញចិត្តលើធាតុចូលកម្មវិធីបណ្តុះបណ្តាល

៣. **ដំណើរការកម្មវិធីបណ្តុះបណ្តាលគរុនិស្សិត**

ការវាយតម្លៃការពេញចិត្តលើដំណើរការកម្មវិធីបណ្តុះបណ្តាល

៤. **លទ្ធផលសិក្សារបស់គរុនិស្សិត**

៥. **ការកសាងសមត្ថភាព និងការអភិវឌ្ឍវិជ្ជាជីវៈ**

ការវាយតម្លៃការពេញចិត្តលើធាតុចេញកម្មវិធីបណ្តុះបណ្តាលរបស់គ្រូចេញថ្មី ( ប្រឡងជាប់បាននិទ្ទេសខ្ពស់ បន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមអង្គភាព)

# ជំពូក៣៖ វិធីសាស្ត្រស្រាវជ្រាវ

- កត់ត្រាទិន្និន័យ Excel, SPSS
- សម្អាតទិន្និន័យ
- បកស្រាយទិន្នន័យតាមសមាសធាតុនីមួយៗ

- វិធីសាស្ត្របរិមាណស័យ
- កម្រងសំណួរ




- ជួបផ្ទាល់ជាមួយគ្រូ
- ការជ្រើសរើសដោយPurposive sampling

( ខេត្តមានគ្រូចេញថ្មី៧នាក់ឡើងទៅ បរិ+២ ជំនាន់ទី១ )

# ជំពូក៤៖ ព័ត៌មានទូទៅ៖ ភេទ មុខវិជ្ជា ការពង្រាយ (កូតា ប៉ុស្ត)តាមខេត្ត

សំណាកខេត្តទាំង៦រួមមាន៖ កំពង់ចាម ៨នាក់ ស្មើនឹង១៦% ព្រៃវែង ១២នាក់ ស្មើនឹង២៤% កណ្ដាល ៧នាក់ ស្មើនឹង១៤% តាកែវ ៨នាក់ ស្មើនឹង១៦% បាត់ដំបង ៨នាក់ ស្មើនឹង១៦% និង ស្វាយរៀង ៧នាក់ ស្មើនឹង១៤%។

សំណាកគ្រូបង្រៀនចេញថ្មីចំនួន ៥០នាក់ ប្រុស ២៤នាក់ ស្មើនឹង ៤៨% និងស្រី ២៦នាក់ ស្មើនឹង៥២% ។ មុខវិជ្ជាឯកទេសចំនួន៤ រួមមាន៖ រូបវិទ្យា ១៣នាក់ ស្មើនឹង២៦ % គីមីវិទ្យា ១១នាក់ ស្មើនឹង ២០ % ជីវវិទ្យា ១៤នាក់ ស្មើនឹង២៨ % និងគណិតវិទ្យា ១២នាក់ ស្មើនឹង ២៤% ។

| | | | |
|---|---|---|---|
| ភេទ | ប្រុស | 24 | 48% |
| | ស្រី | 26 | 52% |
| មុខវិជ្ជាឯកទេស | រូបវិទ្យា | 13 | 26% |
| | គីមីវិទ្យា | 11 | 22% |
| | ជីវវិទ្យា | 14 | 28% |
| | គណិតវិទ្យា | 12 | 24% |
| ខេត្ត | កំពង់ចាម | 8 | 16% |
| | ព្រៃវែង | 12 | 24% |
| | កណ្ដាល | 7 | 14% |
| | តាកែវ | 8 | 16% |
| | បាត់ដំបង | 8 | 16% |
| | ស្វាយរៀង | 7 | 14& |

# ជំពូក៤៖ លទ្ធផលនៃការស្រាវជ្រាវ A. កម្មវិធីបណ្តុះបណ្តាល

## A1. ការពេញចិត្តលើកម្មវិធីបណ្តុះបណ្តាល

ក្រាបទី១បង្ហាញកម្មវិធីបណ្តុះបណ្តាលមានស្ថានភាពល្អលើផ្នែកជាច្រើន។ មធ្យមពិន្ទុតាមលំដាប់ពីលើមធ្យមទៅល្អបង្គួរទៅលើសមាសភាគវង់ទាំង៥ រួមមាន៖ កម្មសិក្សាប្រតិបត្តិគរុកោសល្យ 4.19 មុខវិជ្ជាស្នូលនៃឯកទេស 4.10 មុខវិជ្ជាជម្រើស3.86 មុខវិជ្ជារួមនៃឯកទេស3.85 និងការសរសេរនិក្ខេបបទ3.64 ធៀបទៅនឹងមធ្យមពិន្ទុអប្បបរមា 3.75 ស្មើនឹង 75% ជាប់ស្តង់ដាសាលាគរុកោសល្យគម្រូ។

ការបំពេញបន្ថែមលើការសរសេរនិក្ខេបបទ ការផ្តោតលើមុខវិជ្ជារួម និងមុខវិជ្ជាជម្រើសជាកត្តាអាទិភាព។ ការពង្រីកខ្លឹមសារឱ្យកាន់តែស៊ីជំរៅ និងមានជម្រើសច្រើនប្រកបដោយគំនិតច្នៃប្រឌិត។ ការបង្រួមគម្លាតស្តង់ដាពីមុខវិជ្ជាផ្សេងៗទៀតជាផ្នែកអាទិភាពបន្តក្នុងពង្រឹងគុណភាពកម្មវិធី។



# ជំពូក៤៖ លទ្ធផលនៃការស្រាវជ្រាវ

## A2. ការពេញចិត្តលើគ្រូឧទ្ទេស វិធីសាស្រ្តបង្រៀន និងធនធានរូបវន្ត

ក្រាបទី២បង្ហាញធាតុចូលរបស់កម្មវិធីបណ្តុះបណ្តាលមានស្ថានភាពល្អលើផ្នែកជាច្រើន។ មធ្យមពិន្ទុតាមលំដាប់ពីល្អទៅល្អបង្គួរទៅលើសមាសភាគរងទាំង៦រួមមាន៖ វិធីសាស្រ្តបង្រៀន 4.21 គ្រូឧទ្ទេស ជាគម្រូ 4.16 ការវាយតម្លៃរបស់គ្រូឧទ្ទេស 3.80 ការបង្កើនលទ្ធផលសិក្សារបស់និស្សិត 3.65 ការអនុវត្តវិធីសាស្រ្តបង្រៀន 3.62 និងធនធានរូបវន្តរបស់វិទ្យាស្ថានជាតិអប់រំ 3.61 ធៀបទៅនឹងមធ្យមពិន្ទុអប្បបរមា 3.75 ជាប់ស្តង់ដាសាលាគរុកោសល្យគម្រូ។ ចំណុចដែលត្រូវបំពេញបន្ថែមលើការបង្កើនលទ្ធផលសិក្សា និងការអនុវត្តវិធីសាស្រ្តបង្រៀនជាអាទិភាព។ ធនធានរូបវន្តនៅពេលនោះគឺស្ថិតក្នុងដំណាក់កាលជួសជុល។ ការបង្រួមគម្លាតស្តង់ដា ជាចំណុចអាទិភាព



# ជំពូក៤៖ លទ្ធផលនៃការស្រាវជ្រាវ ៖ សរុបក្នុងផ្នែកទី១ (A1 & A2)

តារាងទី២សរុបផ្នែកទី១ លើធាតុចូលរបស់កម្មវិធី ក្នុងចំណោម 11សមាសភាគមាន 3សមាសភាគដែលមាន មធ្យមពិន្ទុទាបជាងស្តង់ដាអប្បបរមាគឺ3.75 (លើកលែង ធនធានរូបវន្ត)។ លើសពីនេះគម្លាតស្តង់ដាលើផ្នែកទាំង៣ ខាងលើលើសពី 0.7 ជាពិសេសការបង្កើនលទ្ធផលសិក្សា ការអនុវត្តវិធីសាស្ត្រ និងការសរសេរនិក្ខេបបទជាផ្នែកអាទិភាព ដែលត្រូវយកចិត្តទុកដាក់ខ្ពស់។ វិធីសាស្ត្របង្រៀនល្អ គ្រូឧទ្ទេសល្អ អាចចំនួនវិធីសាស្ត្រយកទៅអនុវត្តជាកិច្ចតែងការបង្រៀនឬ ការបង្រៀនសាកល្បងនៅមានកម្រិត។ ក្លឹបសិក្សាទាមទារគ្រូឧទ្ទេសត្រូវបំពេញភារកិច្ចជាអ្នកសម្របសម្រួល ដើម្បីផ្តល់បទពិសោធល្អៗដល់គរុនិស្សិត។ គ្រូដឹកនាំគោល និងគ្រូដឹកនាំរងពង្រឹងយន្តការបន្ថែម។

| សមាសភាគ | សមាសភាគរង | Mean | SD | Sub-sum | Sum |
|---|---|---|---|---|---|
| ការពេញចិត្តលើគ្រូឧទ្ទេស | ធនធានរូបវន្ត | 3.61 | 0.81 | 3.84 | 3.88 |
| | ការអនុវត្តវិធីសាស្ត្រ | 3.62 | 0.81 | | |
| | ការបង្កើនលទ្ធផលសិក្សា | 3.65 | 0.72 | | |
| | ការវាយតម្លៃរបស់គ្រូ | 3.80 | 0.68 | | |
| | គ្រូឧទ្ទេសជាគម្រូ | 4.16 | 0.60 | | |
| | វិធីសាស្ត្របង្រៀនគ្រូ | 4.21 | 0.60 | | |
| ការវាយតម្លៃកម្មវិធីបណ្តុះបណ្តាល | ការសរសេរនិក្ខេបបទ | 3.64 | 0.84 | 3.93 | |
| | មុខវិជ្ជារួមនៃឯកទេស | 3.85 | 0.64 | | |
| | មុខវិជ្ជាជម្រើស | 3.86 | 0.66 | | |
| | មុខវិជ្ជាស្នូលនៃឯកទេស | 4.10 | 0.68 | | |
| | កម្មសិក្សាប្រតិបត្តិ | 4.19 | 0.68 | | |

# ជំពូក៤៖ លទ្ធផលនៃការស្រាវជ្រាវ ៖ ដំណើរការកម្មវិធីបណ្តុះបណ្តាល

## B. ទិន្នន័យទាក់ទងការពេញចិត្តលើដំណើរការកម្មវិធីបណ្តុះបណ្តាល

ក្រាបទី៣បង្ហាញដំណើរការរបស់កម្មវិធីបណ្តុះបណ្តាលមានស្ថានភាពល្អលើផ្នែកជាច្រើនដែលមធ្យមពិន្ទុតាមលំដាប់ពីល្អទៅល្អបង្គួរលើសមាសភាគរងទាំង៦ក្នុងនោះ ប្រព័ន្ធនៃការវាយតម្លៃ 3.99 ដំណើរការកម្មវិធីបណ្តុះបណ្តាល និងឯកសារបណ្តុះបណ្តាល 3.85មានមធ្យមពិន្ទុលើស្តង់ដាអប្បបរមា និង៤ផ្នែកទៀតស្ថិតនៅទាបជាងស្តង់ដារួមមាន៖ រយៈពេលកម្មវិធីបណ្តុះបណ្តាល 3.68 សេវានិស្សិត 3.66 ការតាំងពិពរណ៍ស្នាដៃ 3.61 និង សកម្មភាពគាំទ្រកម្មវិធីបណ្តុះបណ្តាលពីការិយាល័យ 3.36។



# ជំពូក៤៖ លទ្ធផលនៃការស្រាវជ្រាវ ៖ សរុបផ្នែកទី២

**តារាងទី៣សរុបផ្នែកទី២ លើដំណើរការ**

សរុបមកចំណុចដែលត្រូវបំពេញបន្ថែមលើ សកម្មភាពគាំទ្រ ការតាំងពិពរណ៌ និងសេវានិស្សិតជាផ្នែកអាទិភាពដែលត្រូវយកចិត្តទុកដាក់។លើសពីនេះទៀត គម្លាតស្តង់ដា លើ សកម្មភាពគាំទ្រ និងការតាំងពិពរណ៌ ដែលតម្រូវឱ្យការិយាល័យ និងតេប៉ាតឺម៉ង់ដែលទទួលបន្ទុកគួរផ្តោតការយកចិត្តទុកដាក់ជាអាទិភាព។

| សមាសភាគ | សមាសភាគរង | Mean | SD | Sum |
|---|---|---|---|---|
| ការពេញចិត្តលើដំណើរការកម្មវិធី | សកម្មភាពគាំទ្រ | 3.36 | 0.77 | 3.69 |
| | និក្ខេបបទ និងពិពរណ៌ | 3.61 | 0.79 | |
| | សេវានិស្សិត | 3.66 | 0.71 | |
| | រយៈពេលកម្មវិធី | 3.68 | 0.65 | |
| | កម្មវិធី និងឯកសារ | 3.85 | 0.63 | |
| | ប្រព័ន្ធវាយតម្លៃ | 3.99 | 0.66 | |

# **ជំពូក៤៖ លទ្ធផលនៃការស្រាវជ្រាវ** ៖ លទ្ធផលកម្មវិធីបណ្តុះបណ្តាល

**C. លទ្ធផលកម្មវិធីបណ្តុះបណ្តាល (លទ្ធផលកម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ)**

ក្រាបទី៤បង្ហាញធាតុចេញរបស់កម្មវិធីបណ្តុះបណ្តាលក្នុងចំណោម៤សមាសភាគរងមាន២ សមាសភាគដែលមានមធ្យមពិន្ទុលើស្តង់ដាអប្បបរមា ៖ គុណសម្បទាគ្រូចេញថ្មី 3.95 និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ 3.93។ ។ ចំពោះសមាសភាគរងមាន២ទៀតគឺ លទ្ធផលសិក្សារបស់គ្រូចេញថ្មី 3.64 និងការកសាងក្លឹបសិក្សា និងការកសាងសមត្ថភាពសិស្សបន្ថែម 3.41។



## ជំពូក៤៖ លទ្ធផលនៃការស្រាវជ្រាវ ៖ លទ្ធផលកម្មវិធីបណ្តុះបណ្តាល Outputs and Outcomes

សរុបមកចំណុចដែលត្រូវបំពេញបន្ថែមជាអាទិភាពលើសកម្មភាពក្លឹបសិក្សា និងការអភិវឌ្ឍសមត្ថភាព និងលទ្ធផលសិក្សាជាផ្នែកដែលត្រូវយកចិត្តទុកដាក់។ បញ្ហាលើគម្លាតស្តង់ដាលើសមាសភាពក្លឹបសិក្សាដែលជាចំណុចត្រូវពង្រឹងបន្ថែម។

| សមាសភាគ | សមាសភាគរង | Mean | SD | Sub-sum | Sum |
|---|---|---|---|---|---|
| លទ្ធផលសិក្សា | លទ្ធផលសិក្សា | 3.64 | 0.61 | 3.80 | 3.73 |
| | គុណសម្បទា | 3.95 | 0.65 | | |
| សមត្ថភាព និងការអភិវឌ្ឍវិជ្ជាជីវៈ | ក្លឹបសិក្សា និងការអភិវឌ្ឍ | 3.41 | 0.70 | 3.67 | |
| | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | 3.93 | 0.66 | | |

# ជំពូក៤៖ បញ្ហាប្រឈម និងដំណោះស្រាយ

| | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|
| 1 | គុណសម្បទាគ្រូចេញថ្មីគឺវិជ្ជាជីវៈ ប្រំតិបត្តិវិជ្ជាជីវៈ ចរិយាសម្បទា និងសីលធម៌វិជ្ជាជី | បន្តយន្តការត្រួតពិនិត្យតាមដាន បំប៉នសមត្ថភាពទាំងគុណវិឌ្ឍលើឯកទេស វិធិសាស្រ្ត បច្ចេកវិទ្យា ចូលរួមសិក្ខាសាលា ការស្រាវជ្រាវ ហគមន៍សិក្សាវិជ្ជាជីវៈ(PLCs) |
| 2 | លទ្ធផលសិក្សាគ្រូចេញថ្មី<br>ការសរសេរនិក្ខេបបទ ភាសាបរទេស និងមុខវិជ្ជាICT ទទួលបានលទ្ធផលទាប | ពង្រឹងឯកទេស តេស្ត ពង្រឹងវិញ្ញាសាប្រឡង ស្រាវជ្រាវ ដកស្រង់បទពិសោធ ការពង្រឹងបន្ថែមលើការសិក្សាការសរសេរនិក្ខេបបទ ភាសាបរទេស និងមុខវិជ្ជាICT |
| 3 | វិធីសាស្រ្តបង្រៀនការបំប៉ន PLC ការចែករំលែកបទពិសោធ ការគាំទ្រផ្នែកសម្ភារៈពិសោធន៍ ការអនុវត្តវិធីសាស្រ្តបង្រៀនតាមបែបបញ្ញាតិ និងតាមបែបតុក្កតាគំនិតនៅមានកម្រិត | សម្ភារៈពិសោធន៍ ការបំពេញបន្ថែមកម្មវិធី ស្រាវជ្រាវបន្ថែម ការអនុវត្តឱ្យបានញឹកញ៉ាប់ទៅលើវិធីសាស្រ្តទាំងអស់ នៅក្នុងម៉ោងហ្វឹកហ្វឺន។ សិក្សាស្វែងយល់បន្ថែមទៀតអំពីបទពិសោធន៍ អនុវត្តវិធីសាស្រ្តបង្រៀនថ្មីក្នុងក្រុមបច្ចេកទេស |
| 4 | ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀនមានកម្រិតមធ្យម | សិក្ខាសាលាផ្សេងៗទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យា ធ្វើ PLC ចែករំលែកចំណេះដឹង ការបំប៉ន និងបន្ថែមម៉ោង ICT ការបំពាក់សម្ភារៈបរិក្ខា ការស្រាវជ្រាវបន្ថែមជាពិសេសការប្រើ AI |
| 5 | កម្មវិធីឆ្លើយតបទៅនឹងគុណវុឌ្ឍិជាតិការពង្រឹងសមត្ថភាព ការគាំទ្រ និងការត្រួតពិនិត្យ ការបំពេញបន្ថែម និងការស្រាវជ្រាវ | គណៈកម្មការធានាគុណភាពអប់រំកម្ពុជា សិក្សាស្រាវជ្រាវលើចំណុចអាទិភាពដែលអាចដាក់បញ្ចូលបន្ថែមទៀតទៅលើកម្មវិធីបណ្តុះបណ្តាល។ ការពង្រឹងសមត្ថភាពបន្ថែម ការគាំទ្រ និងត្រួតពិនិត្យ ស្រាវជ្រាវបន្ថែម |
| 6 | កម្មវិធីឆ្លើយតបទៅនឹងកម្មវិធីអប់រំការពង្រឹងសមត្ថភាព ការគាំទ្រ និងការត្រួតពិនិត្យ ការបំពេញបន្ថែម និងការស្រាវជ្រាវ | កម្មវិធីឆ្លើយតបទៅនឹងកម្មវិធីអប់រំ ត្រូវត្រួតពិនិត្យកម្មវិធីបណ្តុះបណ្តាលធ្វើការកែលម្អឱ្យស្របនឹងកម្មវិធីអប់រំថ្នាក់ជាតិ |
| 7 | កម្មវិធីឆ្លើយតបទៅនឹងគ្រប់ភាគីពាក់ព័ន្ធ<br>ការពង្រឹងទំនាក់ទំនង ការគាំទ្រ និងការបំពេញបន្ថែម និងការស្រាវជ្រាវ | កម្មវិធីឆ្លើយតបទៅនឹងគ្រប់ភាគីពាក់ព័ន្ធត្រូវសិក្សាស៊ីជម្រៅពីការចង់បានរបស់ភាគីដែលពាក់ព័ន្ធតាមរយៈការធ្វើការស្ទង់មតិ សម្ភាសជាក់ស្តែង |

# ជំពូក៤៖ បញ្ហាប្រឈម និងដំណោះស្រាយ

| | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|
| 8 | ការសរសេរនិក្ខេបបទ | ពង្រឹងការពិនិត្យតាមដានពីគ្រូដឹកនាំគោល និងគ្រូដឹកនាំរង |
| 9 | មុខវិជ្ជាជម្រើសក្នុងចំណោមមុខវិជ្ជាជម្រើស | បន្តធ្វើបច្ចុប្បន្នភាពសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងរដ្ឋបាលអប់រំ សិល្បៈ វប្បធម៌ខ្មែរ និន្នាការអប់រំនិងការអប់រំពេលរដ្ឋពេញលេញ និងភាសាបរទេស |
| 10 | ការបង្កើនលទ្ធផលសិក្សារបស់សិស្ស | បង្កើន១)ការរៀបចំផែនការនិងការកំណត់ចំណុចអាទិភាពសកម្មភាពបង្រៀននិងរៀន ២)ការធ្វើការវិភាគនិងកំណត់ចំណុចដៅក្នុងការបង្រៀន ៣)ការជំរុញនិងលើកទឹកចិត្តសិស្សរៀនយឺត |
| 11 | សេវានិស្សិត (តំណាងការិយាល័យ) | ពង្រឹងសេវាកម្ម ការិយាល័យពាក់ព័ន្ធ មានដូចជាការិយាល័យរដ្ឋបាល ការិយាល័យសិក្សា ការិយាល័យស្រាវជ្រាវ បណ្ណាល័យ |
| 12 | ក្លឹបសិក្សានិងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅមានកម្រិត | រៀបចំយន្តការ ការចូលរួមរបស់គ្រូឧទ្ទេសក្នុងការបង្កើតក្លឹបសិក្សាសម្រាប់សិស្សរៀនយឺត និងរៀនពូកែ ក្លឹបប្រកួតប្រជែង |

# ជំពូក៥៖ សេចក្តីសន្និដ្ឋាន

ក្នុងចំណោម២១សមាសភាគដែលបានលើកយកមកសិក្សាមាន១១សមាសភាគដែលទទួលមធ្យមពិន្ទុខ្ពស់ ៨សមាសភាគទទួលមធ្យមបង្គួរ និង២សមាសភាគដែលទទួលមធ្យមពិន្ទុទាបជាងស្តង់ដាអប្បបរមា។សកម្មភាពគាំទ្រ និងការកសាងក្លឹបសិក្សានិងការអភិវឌ្ឍសមត្ថភាពជាចំណុចអាទិភាពដែលត្រូវចាត់វិធានការ និងពង្រឹងបន្ថែមដើម្បីទទួលបានជាប់ស្តង់ដាពេញលេញ។

ទី១៖ គ្រូចេញថ្មីបានវាយតម្លៃខ្ពស់ដោយពេញចិត្តលើគ្រូឧទ្ទេសរបស់វិទ្យាស្ថានជាតិអប់រំដោយមានមធ្យមពិន្ទុ 3.84 និងលើកម្មវិធីបណ្តុះបណ្តាល 3.93។ សរុប 3.88។

ទី២៖ គ្រូចេញថ្មីបានវាយតម្លៃលើដំណើរការកម្មវិធីបណ្តុះបណ្តាលរបស់វិទ្យាស្ថានជាតិអប់រំដោយមានមធ្យមពិន្ទុសរុប 3.69។

ទី៣៖ គ្រូចេញថ្មីបានវាយតម្លៃលទ្ធផលសិក្សា មានពិន្ទុ 3.80 និងការវាយតម្លៃសមត្ថភាព និងការអភិវឌ្ឍវិជ្ជាជីវៈ 3.67។ សរុបលទ្ធផលសិក្សា 3.73.

| សមាសភាគ | Mean | Sum |
|---|---|---|
| ការពេញចិត្តលើគ្រូឧទ្ទេស | 3.84 | 3.88 |
| ការវាយតម្លៃកម្មវិធីបណ្តុះបណ្តាល | 3.93 | |
| ការពេញចិត្តលើដំណើរការកម្មវិធី | 3.69 | 3.69 |
| លទ្ធផលសិក្សា | 3.80 | 3.73 |
| សមត្ថភាព និងការអភិវឌ្ឍវិជ្ជាជីវៈ | 3.67 | |

# ជំពូក៥៖ សេចក្ដីសន្និដ្ឋាន

ធាតុចូលមានកម្រិតមធ្យមពិន្ទុខ្ពស់ជាងដំណើរការ និងធាតុចេញ។ ការណ៍នេះបង្ហាញពីការខាតបង់នៅក្នុងប្រព័ន្ធ(កម្មវិធីបណ្តុះបណ្តាល) ។ ផ្អែកលើទស្សនទានស្តីពីផលធៀបរវាងការវិនិយោគត្រូវមានសមភាព នឹងផលសម្រេច។ កត្តារារាំងមួយចំនួនដែលជះឥទ្ធិពលអវិជ្ជមានរួមមានសម្ភារៈរូបវន្តស្ថិតក្នុងដំណាក់កាលស្ថាបនាឡើងវិញ កម្មវិធីស្ថិតក្នុងដំណាក់កាលសាកល្បង ការផ្តល់កូតាតាមខេត្តដែលខេត្តមួយចំនួនមានការប្រគួតប្រជែងតិចជាងខេត្តផ្សេងទៀត។ យុទ្ធសាស្ត្រធនធានទាមទារការប្រើប្រាស់ឱ្យមានប្រសិទ្ធជាពិសេសលទ្ធផលខ្ពស់។ កម្មវិធីត្រូវផ្តល់សមត្ថភាពខ្ពស់ក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្ត ការស្រាវជ្រាវ និងឱជីថលសម្រាប់ការបង្រៀន និងរៀន។

ការសិក្សានេះផ្តល់ការទស្សវិស័យក្នុងការវាយតម្លៃកម្មវិធីស្របទៅតាមការរំលឹកទ្រឹស្តីដើម្បីបំពេញបន្ថែមលើការសិក្សានានាដែលមានគម្លាត។ ទ្រឹស្តីវាយតម្លៃកម្មវិធីជាប្រព័ន្ធ (Inputs-Process-Outputs)និងទ្រឹស្តីមួយចំនួនទៀតរួមមាន Kirkpatrick Model និងADDIE Model ដែលជាមូលដ្ឋានក្នុងការវាយតម្លៃកម្មវិធីមានប្រសិទ្ធភាពខ្ពស់។ ការផ្ទៀងផ្ទាត់តាមដំណាក់កាលនីមួយៗអាចជួយគម្រោងកម្មវិធីបណ្តុះបណ្តាលគ្រូអាចកំណត់ពីភាពខ្លាំង និងចំណុចអាទិភាពដែលត្រូវយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវពីគ្រប់ភាគីពាក់ព័ន្ធ។

# ជំពូក៥៖ សេចក្តីសន្និដ្ឋាន

## សំណូមពរ

1. គណៈគ្រប់គ្រង និងការិយាល័យពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់បន្ថែមទៀតលើកង្វល់របស់គរុនិស្សិតដូចបណ្តឹងតវ៉ា តម្រូវការចាំបាច់ពាក់ព័ន្ធនឹងការសិក្សា ការគាំទ្រផ្នែកសតិអារម្មណ៍ សុខភាពសិក្សាជាដើម។
1. គ្រូឧទ្ទេសលើមុខវិជ្ជាជម្រើស និងមុខវិជ្ជាស្នូលនៃឯកទេសពិនិត្យឡើងវិញលើរបៀបនៃការវាយតម្លៃ ការជួយគាំទ្រគរុនិស្សិតដែលទទួលបានលទ្ធផលសិក្សាទាប ការហ្វឹកហ្វឺនវិធីសាស្រ្តបង្រៀន គាំទ្រការសរសេរនិក្ខេបបទរបស់គរុនិស្សិតប្រកបដោយការទទួលខុសត្រូវខ្ពស់។
2. ភាគីពាក់ព័ន្ធ ត្រូវចូលរួមគាំទ្រ ផ្តល់ជាធាតុចូល។
3. ការសិក្សាបន្តអាចក្នុងសំណាកធំជាង ទំនាក់ទំនងរវាងកម្មវិធី និងតម្រូវការនៅតាមវិទ្យាល័យ និងការប្រៀបធៀបក្នុងចំណោមមុខវិជ្ជាឯកទេស។

# ឯកសារយោង


វិទ្យាស្ថានជាតិអប់រំ. (2025). *របាយការណ៍ប្រឡងបញ្ចប់ការបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្ដម (បរិញ្ញាបត្រ+២) ជំនាន់ទី២*.

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា. (2025). *របាយការណ៍លទ្ធផលវាយតម្លៃផ្ដល់ការទទួលស្គាល់គុណភាពអប់រំកម្រិតកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់វិជ្ជាជីវៈគ្រូបង្រៀនកម្រិតឧត្ដម*.

ក្រសួងអប់រំ យុវជន និងកីឡា. (2013). *គោលនយោបាយស្ដីពីគ្រូបង្រៀន*.

ក្រសួងអប់រំ យុវជន និងកីឡា. (2010). *ស្ដង់ដារវិជ្ជាជីវៈគ្រូបង្រៀន*.

NIEC. (2020). *របាយការណ៍របស់វិទ្យាស្ថានជាតិអប់រំសឹង្ហបុរី លើកម្មវិធីសិក្សារបស់វិទ្យាស្ថានជាតិអប់រំកម្ពុជា*.

Ahmadi, S., & Keshavarzi, A. (2013). A survey of in-service training programs effectiveness in teaching skills development from the view-point of students, teachers and principals of guidance schools in Shiraz. *Procedia-social and Behavioral sciences*, *83*, 920-925.

*Guide to AUN-QA assessment at Programme level* (Vol. 4). (2020). ASEAN University Network.

Hite, S. J., De Grauwe, A., De Grauwe, P., Unesco, & Planning, I. I. F. E. (2009). *Capacity development in educational planning and management: Learning from Successes and Failures : a Report of the IIEP-UNESCO Experts' Meeting, Paris, France, 1-2 July 2008*.

NIE International Pte Ltd & Panhchak Research Institute Co., Ltd. (2020). *Review of NIE Cambodia's PRESETT and INSETT curricula for Teacher Training*.

SEAMEO INNOTECH. (2017). *Competency Framework for teachers in Southeast ASIA*

UPI Team. (n.d.). *Teacher education standards, assessment instrument, and quality assurance system in ASEAN countries*.

# សូមអរគុណ!




